# ការសំភាសន៍របស់លោកយាយ ឈឿន ឆេង

**កៈ អ្នកដែលសំភាសន៍ឈ្មោះ ឡាំ ផារីន    ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ឈឿន ឆេង**

## សង្ខេបរបស់លោកយាយ ឈឿន ឆេង

លោកយាយ ឈឿន ឆេង គាត់មានអាយុ ៨៣ ឆ្នាំក្នុងឆ្នាំ២០១៩។ លោកយាយគាត់មិនមានកូននោះទេ សព្វថ្ងៃគាត់នៅលីវ គាត់មានទីលំនៅបច្ចុប្បន្ននៅក្នុង ភូមិ អូចារ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

កៈ ចឹងជាដំបូងជំរាបសួរលោកយាយនាងខ្ញុំមកពីខាងសកលវិទ្យាល័យនៃសហរដ្ឋអាមេរិច ហើយគេបានអោយខ្ញុំមកដើម្បីសុំការអនុញ្ញាត្តិដើម្បីសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយ ថាតើលោកព្វអាចផ្ដល់ឪកាសដើម្បីអោយខ្ញុំ បានសំភាសន៍បានដែលរឺទេលោកយាយ?

ខៈ ចាសបានតែសំរាប់សព្វថ្ងៃនឹងយើងបានរស់នៅជាមួយនឹងក្មួយ។ ហើយសំរាប់ក្មួយយើងគឺគាត់ជានាក់ចិញ្ចឹម។ ហើយនិយាយទៅគឺយើងអត់មានអ្វីនោះទេ ហើយគេបានអោយយើងនឹងហូបចុកចឹងទៅគឺមិនគ្រប់គ្រាន់នោះទេ។ ហើយសំរាប់រាល់ថ្ងៃនឹងគឺយើងបានញ្ញាតិយើងនោះទេ ដែលគាត់បានអោយយើងនឹងហូបខ្លះ។ ហើយសំរាប់ពេលខ្លះនឹងគឺបានញ្ញាតិគាត់បានអោយលុយយើងខ្លះ ៥០០០រៀល ហើយសំរាប់ពេលខ្លះនឹងគឺបាន៣០០០រៀលតាមសធារបស់គេ ហើយយើងបានទៅយកលុយទាំងអស់នឹងយកទៅធ្វើបុណ្យចឹងទៅ។

កៈ ចាសចឹងអរគុណច្រើនលោកយាយ ហើយចឹងសំភាសន៍ដោយនាងខ្ញុំមានឈ្មោះថា ឡាំ ផារីន ហើយសំភាសន៍នូវថ្ងៃទី ៩ ខែ ៣ ឆ្នាំ ២០១៩ ចាសជាដំបូងនាងខ្ញុំចង់សុំស្គាល់ឈ្មោះពេញរបស់លោកយាយថាតើលោកយាយមានឈ្មោះអ្វីដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់ខ្ញុំគឺខ្ញុំមានឈ្មោះថា ឧបាសិកា ឈឿង ឆេង ហើយសំរាប់ខ្ញុំបានរស់នៅសង្កាត់ក្ដល់ ឃុំក្ដល់ ដូនទាវ ស្រុកបាត់ដំបង ខេត្ត បាត់ដំបង។

កៈ ចាសនិយាយទៅសំរាប់ឆ្នាំនឹងថាតើលោកយាយមានអាយុប៉ុន្មានឆ្នាំហើយដែលទៅលោកយាយ?

ខ៖ ចាសសំរាប់ខ្ញុំគឺខ្ញុំមានអាយុ ៨៣ ឆ្នាំហើយសំរាប់ឆ្នាំថ្មីនឹង។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថា សំរាប់លោកយាយមានស្រុកកំណើតនឹងនៅទីកន្លែងណាដែលទៅលោកយាយ?

ខ៖ ចាសសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺទីនេះចំតែម្តង។ ហើយសំរាប់ជំនាន់ពីដើមនឹងគឺខ្ញុំបានរស់នៅខាងក្រោយរបងផ្ទះនេះ ហើយនឹងបានរស់នៅជាមួយនឹងបងប្អូនរបស់យើងរស់នៅជុំគ្នា។ ហើយស្រាប់តែពេលដែលម្តាយរបស់ខ្ញុំបានស្លាប់ ហើយនឹងបងប្អូនរបស់ខ្ញុំបានស្លាប់អស់ចឹងទៅគឺនៅសល់តែខ្ញុំម្នាក់ហើយនឹងនៅក្មួយម្នាក់នោះទេ។ ហើយសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹង នោពេលដែលគេបានជំលៀសយើងអស់ចឹងទៅ គឺយើងនៅសល់តែរស់នៅជាមួយឪពុកហើយនឹងម្តាយចឹងទៅ ហើយដល់ពេលចឹងគឺគាត់បានរស់នៅជាមួយម្តាយរបស់ខ្ញុំចឹងទៅ ហើយដល់រស់នៅជាមួយម្តាយរបស់យើង ហើយនៅពេលដែលម្តាយរបស់យើងបានបាត់ទៅក៏គេបានយកយើងនឹងអោយទៅរស់នៅជាមួយគេ។ ហើយនិយាយទៅគឺយើងនៅពេលនឹងគឺបានតែមួយរស់ៗនោះទេ។ ហើយសំរាបការងារនឹងគឺមិនសូវជាធំដុំនោះទេ គឺគាត់បានធ្វើការងារសំណង់នោះទេ។ ហើយនិយាយទៅគឺយើងបានគ្រាន់តែមួយកេៗនឹងឯង។

ក៖ ចាសចឹងចង់សួរលោកយាយបន្តិចថា សំរាប់លោកយាយមានបងប្អូនទាំងអស់ចំនួនប៉ុន្មាននាក់ដែលទៅលោកយាយ?

ខ៖ចាសនិយាយទៅសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺអស់ហើយ គឺនៅសល់តែម្នាក់ឯងគត់នឹង។

ក៖ ចាសតែចង់សួរថាសំរាប់លោកយាយពីមុននឹងថាតើលោកយាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពីមុននឹងគឺខ្ញុំមានបងប្អូននឹងចំនួន ៤ នាក់។ហើយសំរាប់ទី១ ដែលនៅក្នុងជំនាន់ប៉ុលពតនឹងគឺគេបានយកគាត់ទៅគឺជាបងស្រីរបស់យើង។ ហើយសំរាប់ទី២គាត់បានកើតរោគ។ ហើយសំរាប់ទី៣គឺខ្ញុំតែម្តង ហើយសំរាប់ទី៤ គឺគាត់បានស្លាប់តាំងពីឆ្នាំ ១៩៦១ ។ហើយនិយាយទៅគឺបានស្លាប់អស់ហើយគឺនៅសល់តែខ្ញុំម្នាក់គត់។

ក៖ ចាសហើយចង់សួរលោកយាយ បន្តិចថាសំរាប់បងប្អូនរបស់លោកយាយទាំង៤នាក់នឹងថាតើគាត់មានឈ្មោះអ្វីដែលទៅលោកយាយ?

ខ៖ ចាសសំរាប់បងទី១របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ឈឿង ចឹម ហើយសំរាប់បងទី២របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ឈឿង គី ហើយសំរាប់ទី៣គឺគាត់មានឈ្មោះថា ឈឿង ឆេង ហើយសំរាប់បងប្អូនទី៥របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ឈឿង អេង ។

ក៖ ចាសហើយចឹងនៅពេលដែលបងប្អូនរបស់លោកយាយគាត់បានស្លាប់នឹងថាតើពួកគាត់មានគ្រួសារដែលមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់បងទី១របស់ខ្ញុំនឹងគឺគាត់មានគ្រួសារហើយតែគេបានយកគាត់ទៅសំលាប់ចោលបាទហើយ។ហើយនិយាយទៅសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងគឺគេបានសំលាប់ចោលអស់ហើយ។ ហើយសំរាប់បងទី២នឹងគឺគាត់មិនមានគ្រួសារនោះទេ។ ហើយសំរាប់មកដល់ខ្ញុំនឹងគឺអត់មានទាំងប្តីហើយនឹងអត់មានទាំងកូនទៀត។ ហើយសំរាប់ប្អូនទី៥របស់ខ្ញុំនឹងក៏គាត់នៅលីវមិនទាន់មានដែល។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថា សំរាប់លោកយាយនៅពីក្មេងនឹងថាតើលោកយាយបានទៅសាលារៀនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ខ្ញុំនៅក្នុងជំនាន់នឹងគឺរៀនបានតែ២ឆ្នាំនោះទេ។ ហើយណាមួយទៀតនឹងគឺយើងកំព្រាឪពុកហើយនឹងម្តាយរបស់យើង។ ហើយនិយយាទៅគឺខ្ញុំបានកំព្រានឹងគឺតាំងពីខ្ញុំមានអាយុ៧ឆ្នាំ។ ហើយយើងបានរស់នៅតែជាមួយម្តាយរបស់យើងនោះទេ។ ហើយសំរាប់បងប្អូនរបស់យើង៥នាក់នឹងគឺចេះតែនាំគ្នាដើម្បីរស់ចឹងទៅ។ ហើយយើងទាំងអស់នឹងគឺមិនមានមុខរបបអ្វីនោះទេ ហើយយើងបានឪពុកធំរបស់យើងបានគាត់បានដឹកនាំយើងនឹងអោយធ្វើស្រែចំការនឹងជាមួយគ្នា។ ហើយសំរាប់បងទី១របស់ខ្ញុំនឹងគឺគាត់បានធ្វើនុំសំរាប់លក់ដើម្បីចិញ្ចឹមម្តាយហើយនឹងបងប្អូនទាំងអស់ចឹងទៅ។ ហើយសំរាប់មកដល់បងទី២របស់យើងវិញគឺលោកគាត់បានឃើញហើយនឹងមានចិត្តណានិត។ ហើយក៏បានបបួលគាត់នឹងអោយទៅរស់នៅជាមួយលោក ហើយនឹងបានបួសនៅរៀនជាមួយនឹងលោកចឹងទៅ។ ហើយសំរាប់យើងនឹងគឺយើងមិនបានរស់នៅជាមួយនឹងគ្នានោះទេ។ ហើយសំរាប់យើយងក៏បានកំព្រាឪពុករបស់យើង ហើយក៏បានរស់នៅជាមួយនឹងម្តាយ ហើយនឹងបានរកលក់ដូរដូចជានុំអីចឹងទៅ។ ហើយដល់ពេលចឹងគឺយើងក៏បានរស់នៅជាមួយគាត់ហើយក៏ចិញ្ចឹមពួកគាត់តែម្តង។ ហើយនិយាយទៅសំរាប់ជីវិភាពរបស់ខ្ញុំនឹងនៅក្នុងជំនាន់នឹងគឺមានភាពកំសត់ខ្លាំងណាស់។ ហើយនៅពេលដែលមកសំភាសន៍នឹងថាតើយើងបានមកជួយជនដែលក្រក្រីដែលរឺទេ។

ក៖ ចាសនិយាយទៅសំរាប់ខាងសាលារៀនរបស់យើងនឹងគឺមិនបានជួយដល់អ្វីនោះទេ តែសំរាប់យើងចង់បានប្រវត្តិរបស់លោកយាយដើម្បីយកមកចងក្រងធ្វើជាសៀវភៅសំរាប់ចែកចាយអោយក្មេងៗជំនាន់ក្រោយនឹងបានដឹងអំពីជិវិតរបស់លោកយាយមានភាពលំបាកយ៉ាងមិច។ លោកយាយ?

ខ៖ ចាសនិយយាទៅសំរាប់ខ្ញុំនឹងគឺមានភាពវេទនាខ្លាំងណាស់ ហើយសំរាប់យើងនឹងគឺមិនបានជួយអ្វីនោះទេគ្រាន់តែនៅចាំផ្ទះ ហើយសំរាប់កូនចៅរបស់យើងនឹងគឺបានចេញទៅក្រៅអស់ចឹងទៅដើម្បីទៅធ្វើការងារសំណង់អស់ចឹងទៅ។ ហើយសំរាប់យើងនៅពេលដែលយើងបានក្រោកពីម៉ោង ៨កន្លះមកចឹងទៅគឺយើងបានដាំបាយដាំអីអោយគេបានស្រាប់ចឹងទៅ ហើយនៅពេលដែលគេបានចេញមកម៉ោង ១១ អីនឹងក៏គេបានមកធ្វើទុក្ខសំរាប់ពេលល្ងាចមកនឹងក៏មានម្ហូបនឹងស្រាប់សំរាប់ហូបចឹងទៅ។ ពីព្រោះអីនឹងសំរាប់ខ្ញុំនឹងគឺធ្វើអ្វីមិនបាននោះទេតាំងពីខ្ញុំបានកាន់កំសៀវហើយទឹកក្តៅនឹងគឺបានស្រោចមកត្រូវជើងរបស់ខ្ញុំនឹងវាធ្វើអោយរលាកទឹកក្តៅនឹងគឺធ្វើមិនចង់បាននោះទេ។ ហើយនៅពេលដែលស្រោចជើងរបស់យើងហើយចឹងគឺក្មួយរបស់យើងនឹងគឺគាត់បាននិយាយថាសំរាប់ពេលក្រោយនឹងគឺអោយឈប់ធ្វើ។ ហើយដល់ពេលចឹងក៏គេបានលើកគ្រែមកអោយមកអង្គុយនៅខាងក្រៅដើម្បីអោយបានត្រជាក់។ ពីព្រោះអីនឹងនៅខាងក្នុងនឹងគឺវាក្តៅខ្លាំងណាស់។ ហើយនិយាយទៅនៅពេលដែលខ្ញុំបាននៅចាំផ្ទះចឹងគឺនូវមានពួកអាជើងបោកប្រាស់យើងទៀត។ ហើយនិយាយទៅគឺដូចជារបស់របបដែលគេបានយកមកធ្វើជាជាងសំណង់។គឺគេបាននិយាយថា មេជាងនឹងគឺបានអោយមកយក។ ហើយនៅពេលនឹងគឺយើងបាននិយាយថាមិនមានចឹងនោះទេ ចាំខ្ញុំខលទៅសួរកូនរបសយើងសិន។ ហើយសំរាប់គាត់នឹងគឺបានយករបស់អ្វីនោះទេចេញពីហោប៉ាវរបស់គាត់នឹងគឺរាងតូចដែល។ ហើយគ្រាន់តែគាត់នឹងបានយកមកចេញមកនឹងគឺធ្វើអោយយើងនឹងរឹងធ្មៀមរបស់យើងនិយាយលេងរួចតែម្តង។ ហើយដល់ពេលចឹងពួកវានឹងបានធ្វើបាបយើងតែម្តង។

ក៖ ចាហាសើយចឹងនៅពេលដែលគាត់បានដាក់ចឹងគឺយើងមិនបាត់បង់របស់ទាំងអស់នឹងហើយមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅគឺយើងបានបាត់បង់របស់របបដែលគេបានយកទៅធ្វើជាជាងសំណង់នឹងចំនួន២ ។ ហើយសំរាប់មួយនឹងមានតំម្លៃ ១០០ដុល្លា។ ហើយសំរាប់ម្នាក់ទៀតនឹងគឺគេបានបញ្ជេះម៉ូតូគឺគេមិនបានបិទនោះទេ។ហើយសំរាប់ម្នាក់ទៀតនឹងគឺវាបានចូលមកធ្វើបាបយើង។

ក៖ ចាសហើយចឹងសំរាប់នាក់ដែលបានរស់នៅជិតខាងនឹង ថាតើគេមិនបានជួយយើងនោះទេមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ផ្ទះមួយទៀតនឹងគឺគេបានទៅទិញអេតចាយអស់ចឹងទៅ។ ហើយណាមួយទៀតនឹងគឺផ្ទះរបស់យើងនឹងគឺគេបានចេញទៅធ្វើការងារអស់ចឹងទៅ។ ហើយសំរាប់កូនក្មេងនឹងគឺគេបានទៅរៀនអស់ទៀត។ ហើយប្រសិនជាទុកហើយនឹងគ្រាន់តែយើងចង់និយាយថាយកទូរសព្ទ៍ចុកទៅបន្តិចនឹងគឺវានឹងបានយករបស់នឹងមកនឹងគឺធ្វើអោយយើងនឹងរឹងផ្អៀមរបស់យើងតែម្តង។ ហើយសំរាប់នាក់ដែលនិយាយក៏និយាយចឹងទៅ ហើយសំរាប់នាក់ដែលចូលមកយកនឹងគឺគេបានចូលយកចឹងទៅ។ ហើយចឹងបានថាសំរាប់ពេលនឹងមកនឹងគឺខ្ញុំមិនហ៊ាននឹងបើកទ្វានោះទេ។គឺខ្ញុំបិទទ្វាជិតៗ។ហើយដល់ពេលចឹងគឺធ្វើអោយខ្ញុំនឹងរាងចាលតែម្តង។

ក៖ ចាសនិយាយទៅតាមពិត គឺយើងគួរតែមានការប្រុងប្រយត្ន័។ ពីព្រោះអីនឹងគឺខ្ញុំគិតថាយើងនឹងបានរស់នៅម្នាក់ឯង។លោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់រឿងមួយនឹងគឺយើងមិនបានដឹងដែល។ ហើយវាបានដឹងតាមខ្សែរយះតាមនាក់ណាគេអីនឹងក៏យើងមិនបានដឹងដែល។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថាសំរាប់សាលារៀនដែលលោកយាយបានរៀននៅក្នុងជំនាន់នឹងថាតើសាលាលរៀននឹងមានឈ្មោះអ្វីដែលទៅលោកយាយ?

ខ៖ ចាសសំរាប់មួយនឹងគឺថានៅពេលដែលខ្ញុំបានរៀននៅក្នុងជំនាន់មុននឹងគឺមានឈ្មោះថាសាលារៀនវត្តក្តល់។

ក៖ ចាសហើយចឹងបានន័យថាសំរាប់សាលារៀនវត្តក្តល់នឹងគឺមានតាំងពីជំនាន់មុនរហូតមកដល់លូវនឹងតែម្តងមែនដែលរឺទេលោកយាយ?

ខ៖ ចាសៗ ហើយនិយាយទៅសំរាប់ពេលដែលយើងរៀននឹងគឺគេមានចំនួន៣ថ្នាក់។ ហើយសំរាប់ពេលនឹងគឺគេមិនបានរាប់ថ្នាក់ទី១ទៅថ្នាក់៣អីដូចជាលូវនឹងនោះទេ។ ហើយនិយាយទៅគឺគេបានរាប់ពីថ្នាក់ទី៥មុន ហើយបានមកដល់ថ្នាក់ទី៤ ហើយបានមកដល់ថ្នាក់ទី៣ ទី២ ហើយនឹងទី១។ ហើយបានយើងអាចប្រលងធ្វើជាគ្រូបាន។នឹងសំរាប់ជំនាន់របស់ខ្ញុំដែលបានរៀន។

កៈ ចាសហើយចឹងសំរាប់នៅក្នុងជំនាន់របស់លោកយាយ ថាតើគេមានរៀនភាសាអ្វីក្រៅពីភាសាបាំរាំងដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅគឺគេបានរៀនភាសាបាំរាំង។

កៈ ចាសហើយចឹងសំរាប់លោកយាយថាតើលោកយាយបានរៀនភាសាបាំរាំងនឹងដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅគឺខ្ញុំមិនបានរៀននោះទេ។ ពីព្រោះអីនឹងគឺយើងបានរៀនបានតែថ្នាក់ទី ៥ តែប៉ុននឹង។ ហើយនិយាយទៅគឺយើងបានរៀននឹងគឺបានតែ២ថ្នាក់នោះទេ។ ពីព្រោះអីនឹងសំរាប់ពេលនឹងគឺយើងកំព្រា។ ហើយណាមួយទៀតនឹងនៅពេលនឹងគឺយើងបានតែឪពុកធំរបស់យើងនោះទេ។ ហើយឪពុកធំរបស់យើងគាត់ក៏បាននិយាយថាប្រសិនជាកូនអត់មានចឹងគឺអោយទៅធ្វើស្រែជាមួយឪពុកទៅកូន នឹងគឺគាត់បាននិយាយថា។ ហើយដល់ពេលចឹងគឺយើងបានទៅរៀនរួសហើយនឹងធ្វើការងារជាមួយគាត់ចឹងទៅ។ ហើយសំរាប់បងរបស់យើងនឹងគឺគាត់ដឹងតែធ្វើនុំសំរាប់លក់ចឹងទៅ។ ហើយគាត់បានចិញ្ចឹមយើងទាំងអស់គ្នា។

កៈ ចាសហើយចឹងបានន័យថាសំរាប់លោកយាយគឺចេះភ្ជួររាស់ទៀតមែនដែលរឺទេលោកយាយ ហើយចេះភ្ជួរដោយខ្លួនឯងទៀតលោកយាយមែនដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅគឺយើងភ្ជួររាស់នឹងគឺដោយខ្លួនយើងជាមួយឪពុករបស់យើង។ ហើយនិយាយទៅសំរាប់ការងារមួយនឹងគឺយើងចេះតែពីឆ្នាំ ១៩៥៨ មកម្លេស។ ហើយបានមកដល់ឆ្នាំ ១៩៦៤ នឹងបានប្អូនស្រីពៅរបស់យើងនឹងក៏គាត់បានស្លាប់តែម្តង។

កៈ ចាសហើយចឹងសំរាប់ប្អូនពៅរបស់លោកយាយដែលបានស្លាប់នឹងគឺគាត់បានកើតជំងឺនឹងមែនដែលរឺទេលោកយាយ?

ខៈ ចាសៗ។

កៈ ចាសហើយចឹងចង់សួរលោកយាយបន្តិចថា សំរាប់ឪពុករបស់លោកយាយថាតើគាត់មានឈ្មោះអ្វីដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ឈឿង ឆេង។

កៈ ចាសហើយចឹងសំរាប់ម្ដាយរបស់លោកយាយថាតើគាត់មានឈ្មោះអ្វីដែលទៅលោកយាយ?

ខៈ ចាសសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា សេង ។

កៈ ចាសហើយចឹងសំរាប់ឪពុកហើយនឹងម្ដាយរបស់លោកយាយ ថាតើនៅពេលដែលគាត់បានស្លាប់នឹងថាតើគាត់មានអាយុប៉ុន្មានដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់មួយនឹងគឺខ្ញុំបានភ្លេចបាត់ហើយ។

កៈ ចាសហើយចឹងចង់សួរលោកយាយមួយទៀតថា សំរាប់ស្រុកកំណើតឪពុកហើយនឹងម្ដាយរបស់លោកយាយថាតើពួកគាត់នៅទីកន្លែងណាដេលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់ស្រុកកំណើតរបស់ពួកគាត់នឹងគឺនៅទីកន្លែងនឹងឯង។ គឺនៅខាងក្ដល់នឹង។ ហើយនិយាយទៅគឺនៅឃុំក្ដល់។

កៈ ចាសហើយចឹងចង់សួរបន្ថិថាសំរាប់លោកយាយបានរស់នៅទីកន្លែងនេះនឹងតាំងពីដូនតារបស់លោកយាយតែម្ដងមែនដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់ស្រុកកំណើតរបស់ពួកគាត់នៅទីកន្លែងនឹងតែម្ដង។ ហើយសំរាប់ផ្ទះនោះទេក៏ទើបតែកើតមកថ្មី ហើយនៅទីកន្លែងនោះមួយទៀតនឹងក៏ទើបតែកើតមកថ្មីដែល។ ហើយសំរាប់នៅក្នុងជំនាន់ពីដើមនឹងគឺមានតែផ្ទះនៅទីកន្លែងនឹងមួយ ហើយនឹងនៅខាងក្រោយនឹងគឺមានមួយទៀត។

កៈ ចាសហើយចឹងចង់សួរលោកយាយបន្ដិចថា សំរាប់នៅក្នុងជំនាន់ពីដើមនឹងថាតើកន្លែងនេះមានផ្លូវដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់ពីដើមនឹងគឺគេមានផ្លូវតែគេមិនបានចាក់កៅស៊ូនោះទេ។ ហើយនិយាយទៅគឺមានតែផ្លូវលំនោះទេ។

កៈ ចាសហើយចឹងសំរាប់ប្រឡាយនឹងថាតើយើងមានស្រាប់នោះទេមែនដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់លូនឹងគឺខ្ញុំបានឃើញតាំងពីខ្ញុំបានកើតមកនឹងគឺបានឃើញវា។

កៈ ចាសហើយចឹងបានន័យថាសំរាប់លូវនឹងគឺមានភាពវ៉ៃយចំចាស់ហើយ ពីព្រោះអីនឹង ប្រសិនជាគិតអាយុនឹងគឺយូរហើយមែនដែលរឺទេលោកយាយ?

ខៈ ចាសនិយយាទៅគឺយូរហើយ ណាមួយទៀតនឹងគឺវាបានកើតមកតាំងពីជំនាន់លោកតា របស់ខ្ញុំម្លេស។ចាស។

កៈ ចាសហើយចឹងចង់សួរលោកយាយបន្តិចថា សំរាប់លោកយាយបានមករស់នៅទីកន្លែង នេះរហូត គឺមិនបានផ្លាស់ប្តូរទៅកន្លែងផ្សេងទៀតនោះទេមែនដែលរឺទេលោកយាយ?

ខៈចាសនិយាយទៅគឺមិនបានប្តូរនោះទេ។ ហើយសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងគឺគេបាន យកខ្ញុំនឹងទៅសំលាប់នៅខាងបឹងខ្នឹង។ ហើយនិយាយទៅគឺគេបានយកខ្ញុំទៅសំលាប់។ ហើយណាមួយទៀតនឹងគឺខ្ញុំមានអាយុវែងហើយនឹងសំណាង។ ហើយក៏បានដោះស្រាយ ជាមួយគេបានចឹងទៅក៏បានមានជីវិតរស់នៅបានមកដល់សព្វថ្ងៃនឹង។ ហើយសំរាប់ខ្ញុំបាន បុណ្យរហូតតាំងពីឆ្នាំ ១៩៨០ គត់មក។ហើយសំរាប់ខ្ញុំបានទៅរៀនខាងសមាធិនៅវត្តពោធ៍ក្នុ ង។ ហើយនិយយាទៅគឺយើងបុណ្យរហូតធ្វើយ៉ាងមិចអោយតែម្តាយរបស់យើងបានរស់នៅ។ គឺយើងសុទ្ធចិត្តទៅធ្វើបួស។

កៈ ចាសហើយចឹងចង់សួរលោកយាយបន្តិចថាសំរាប់នៅក្នុងជំនាន់ប៉ុលពត នឹងថាតើលោក យាយបានរស់នៅទីកន្លែងនឹងដ៏ដែលមែនដែលរឺទេលោកយាយ?

ខៈ ចាសៗនិយយាទៅសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងគឺខ្ញុំបានរស់នៅទីកន្លែងនឹងដ៏ដែល។

កៈ ចាសហើយចឹងបន្ទាប់ពីសម័យប៉ុលពតហើយចឹង ថាតើគេបានជំលៀសលោកយាយទៅ ដល់ទីកន្លែងណាខ្លះដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងគឺគេបានជំលៀសនឹងតែបងប្អូនរបស់ខ្ញុំ នឹងបានទៅដល់ ដីទួលតាផ្តេ។ ហើយបានថានៅពេលដែលគាត់បានត្រឡប់មកវិញនឹងអត់ ឃ្លានពេកចឹងក៏គាត់បានស្លាប់តែម្តង។

កៈ ចាសហើយចឹងបានន័យថាសំរាប់បងប្អូនរបស់លោកយាយ គឺគាត់បានស្លាប់នៅក្នុងជំនាន់ ប៉ុលពតនឹងតែម្តងមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់នៅសម័យប៉ុលពត ១ម្នាក់។ ហើយសំរាប់នៅក្នុងសម័យនេះនឹងគឺអស់២នាក់ទៀត។ ហើយមកដល់លូវនឹងគឺនៅសល់តែយើងម្នាក់នោះទេ។

ក៖ ចាសហើយចឹងចង់និយាយថាសំរាប់លោកយាយបានរស់នៅជាមួយនឹងម្ដាយរបស់លោកយាយរហូតមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺយើងបានរស់នៅជាមួយម្ដាយរបសយើងរហូត។ ហើយបានមកដល់ឆ្នាំ ១៩៩៨ នឹងបានម្ដាយរបស់ខ្ញុំនឹងបានស្លាប់បាត់ហើយ។ ហើយសំរាប់នាក់ដែលបានរស់នៅជាមួយម្ដាយនឹងក៏គាត់បាននាំខ្ញុំនឹងមកនៅជាមួយម្ដាយរបស់គេ។

ក៖ ចាសហើយចឹងសព្វថ្ងៃលោកយាយបានរស់នៅជាមួយនឹងក្មួយ ហើយដោយសារតែក្មួយរបស់លោកយាយបានចិញ្ចឹមលោកយាយមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ក្មួយគាត់បានមើលថៃយើងនឹង ហើយនឹងគ្រប់គ្រងយើង។ ហើយសំរាប់ម្ហូបក៏មានហើយនឹងមានសំល្លៀកបំពាក់នឹងគឺមានគ្រប់សព្វតែម្ដង។ ហើយនិយាយទៅគឺមួយចប់។ ពីព្រោះអីនឹងគឺយើងអត់មានកូនចៅនោះទេ។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថាសំរាប់លោកយាយ នៅក្នុងជំនាន់ប៉ុលពត ថាតើថាលោកយាយបានរស់នៅទីកន្លែងណា ហើយនឹងគេបានអោយលោកយាយបានធ្វើការងារអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសមរាប់នៅក្នុងជំនាន់នឹងគឺគេបានអោយយើយងនឹងទៅរស់នៅខាង បឹងសំភាសន៍ នៅជាប់អាងបឹងខ្វឹង។ ហើយពេលនឹងគឺគេបានយកយើងនឹងទៅសំលាប់ទៀត។តែសំរាប់យើងពេលនឹងគឺយើងមិនបានស្លាប់។

ក៖ ចាសហើយចឹងមូលហេតុអ្វីបានជាគេបានយកលោកយាយទៅឆ្ងាយចឹង ហើយនោពេលដែលលោកយាយទៅនឹងថាតើគេបានអោយម្ដាយរបស់លោកយាយទៅជាមួយលោកយាយដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅគឺគេបាននាំយើងនឹងទៅតែម្នាក់ឯងនោះទេ។ ហើយសំរាប់ពេលនឹងគឺគេបានស្អប់យើង។ហើយគេបានចោទយើងនឹងគឺជាពួកនាទន់ពពួកថ្នាក់កណ្ដាល។ ហើយណាមួយទៀតនឹងគឺពួកគាត់បានឃើញបងរបស់ខ្ញុំនឹងបានធ្វើនុំសំរាប់លក់ ហើយបងប្អូនរបស់ខ្ញុំនឹងនៅផ្ទះដើម្បីចិញ្ចឹមម្ដាយរបស់យើង។ ហើយសំរាប់យើងបានទៅធ្វើស្រែជាមួយឪពុកធំចឹ

ងទៅ ហើយនៅពេលដែលយើងបានមកក៏ពួកគេបានចោទយើងនឹងគឺជាពួកនាទន់នៅចំថ្នាក់កណ្តាល។ ហើយគេបាននិយាយថាសំរាប់គេចង់ដកយើងចេញក៏មិនខាត ហើយទុកយើងក៏មិនចំនេញដែល។នឹងសំរាប់នៅក្នុងជំនាន់ប៉ុលពត។ ហើយនិយយាទៅគឺគេបាននិយាយ។ ហើយសំរាប់ក្មួយឯងដែលបានលឺដែរឺទេគេនិយាយថាសំរាប់ទុកយើងនឹងក៏មិនចំនេញ ពីព្រោះអីនឹងអស់បាយហើយនឹងម្ហូបអាហាររបស់គេ។ហើយនៅពេលដែលដកចេញនឹងក៏វាមិនខាតដែល។ ហើយនិយាយទៅគឺគេបាននិយាយថាដកចេញក៏ខាត ហើយទុក្ខនឹងក៏មិនចំនេញដែល។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថា នៅពេលដែលលោកយាយនៅពីក្មេងចឹង សំរាប់ឪពុកហើយនឹងម្តាយរបស់លោកយាយថាតើពួកគាត់បានប្រកបមុខរបបអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពួកគាត់គឺមិនបានធ្វើអ្វីនោះទេ។ គឺពួកគាត់ធ្វើតែនុំសំរាប់លក់នោះទេ។

ក៖ ចាសហើយចឹងសំរាប់ឪពុកហើយនឹងម្តាយរបស់លោកយាយថាតើពួកគាត់បានធ្វើនុំអ្វីសំលក់ដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅគឺឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺកាត់បានធ្វើអាកោ ហើយនឹងនុំតាឡៃលក់។ ហើយនិយាយទៅគឺជានុំដែលបានធ្វើចេញពីផ្លែត្នោត។ ហើយនោពេលដែលយើងអត់មានពីឪពុករបស់យើងចឹងទៅគឺយើងក៏បាននាំគ្នានឹងចេញរកស៊ីតែម្តង។ ហើយសំរាប់យើងនឹងក៏អោយបងប្អូនជីដូនមួយនឹងអោយគាត់នឹងជួយចិញ្ចឹមតែម្តង។ ហើយដល់ពេលចឹងគឺគាត់បាននិយាយថាអោយយើងនឹងរៀនតែប៉ុននឹងទៅបានហើយ ហើយអោយយើងនឹងទៅធ្វើស្រែ។ ហើយដល់ពេលចឹងបានយើងនឹងបានរៀនប៉ុននឹងក៏បានទៅធ្វើស្រែចឹងទៅ។

ក៖ ចាសហើយចឹងនៅពេលដែលយើងនឹងទៅធ្វើស្រែនឹងថាតើលោកយាយបានទៅធ្វើដល់ណាដែលទៅលោកយាយ?

ខ៖ ចាសនិយាយៅទគឺយើងបានធ្វើនឹងគឺឆ្ងាយដែល។ ហើយប្រហែលជា៣គីឡូរពីកន្លែងនេះ។ ហើយសំរាប់កន្លែងនឹងគឺគេបានហៅថាប្រាំយាំម។ ហើយពីនឹងទៅគឺឆ្ងាយគួរសមដែល។ ហើយសំរាប់យើងនៅពេលដែលដល់ម៉ោង ៣ព្រឹករឺក៏ម៉ោង៤ព្រឹកនឹងគឺយើងបានក្រោកឡើង ហើយបាននាំគ្នានឹងគឺទៅធ្វើការងារហើយ។

កៈ ចាសហើយចឹងសំរាប់នៅក្នុងជំនាន់នឹងនៅពេលដែលយើងនឹងបានទៅធ្វើស្រែនឹងគឺយើងបានក្រោកពីយប់ទៅមែនដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅគឺយើងបានក្រោកពីយប់ទៅធ្វើការងារទាំងអស់នឹង។ ហើយនិយាយទៅសំរាប់នៅក្នុងជំនាននឹងគឺយើងពិបាកខ្លាំងណាំស់ ហើយមិនដូចជានៅក្នុងសម័យនេះនោះទេគឺគេបានធ្វើការងារនឹងគឺជឿនលឿនខ្លាំងណាស់។ ហើយសំរាប់ក្មេងៗនៅក្នុងជំនាន់នេះនឹងគឺពាក់ខោនឹងគឺបានរឹបអស់ហើយសំរាប់ខោរបស់គេ។ ហើយសំរាប់នៅក្នុងជំនាន់មុនវិញនឹងគឺមិនចឹងនោះទេ សំរាប់សំពតរបស់គេពាក់នឹងគឺថាត្បាញ់ដែលចេញរវៃមក។ដែលមានលោកគាត់បានបួស។ ហើយសំរាប់តាមថ្មេនឹងគឺមានចៃតាមនឹង។ ហើយនិយាយទៅគឺថារវាស់ខ្លាំងណាំស់។

កៈ ចាសហើយចឹងនៅពេលដែលយើងបានត្បាញ់តាមក្របាស់នឹងគឺយើងមានចៃមែនដែលរឺទេលោកយាយ?

ខៈ ចាស។

កៈ ចាសនិយាយទៅនៅពេលដែលសំពតដែលបានមកពាក់នឹងថាតើវាតាន់ដូចជានេះដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅគឺវាដូចចដែល។តែសំរាប់សាច់សំពតនឹងគឺមានរាងក្រឹបបន្តិច។ ហើយណាមួយទៀតនឹងគឺសាច់របស់វាគឺធំៗ។ ហើយនិយាយទៅសំរាប់មួយនឹងគឺសាច់របស់វានឹងគឺសៗ។

កៈ ចាសហើយចឹងយើងបានធ្វើយ៉ាងមិចដែលទៅលោកយាយបានយើងអាចនឹងយកមកធ្វើហើយនឹងត្បាញ់វាបានដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់មួយនឹងគឺយើងពិបាកនិយាយខ្លាំងណាស់ ហើយប្រសិនជាយើងបានរាប់អំពីប្រវត្តិរបស់យើងវិញនឹងគឺមិនអស់នោះទេ។

កៈ ចាសនិយាយទៅចង់សួរកាត់លោកយាយបន្តិចថាសំរាប់ ក្របាស់នឹងថាតើយើងបានធ្វើយ៉ាងមិចដែលទៅលោកយាយបានយើងអាចយកមកត្បាញ់ធ្វើជាក្រណាត់សំពតបានពាក់បានដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅនៅពេលដែលគេបានយកមកគឺខ្សៀប ហើយនឹងយកគ្រាប់របស់វានឹងចេញចឹងទៅ ហើយក៏បានយកធ្វើជាសរសៃអំបោះតូចៗចឹងទៅ។

ក៖ ចាសនិយាយទៅសំរាប់មួយនឹងគឺយើងអាចយកមកធ្វើជាសរសៃអំបោះបានទៀតមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅគេបានយកមកនឹងគឺគេបានហៅរបស់ទាំងអស់នឹងគឺជារហាត់។ នឹងសំរាប់វត្ថុធាតុដើម។ ហើយនៅពេលដែលគេបានយករបស់ទាំងអស់នឹងមក ហើយនឹងក៏បានយកអំបោះមកហើយក៏គេបានដំាបបរ ហើយនឹងធ្វើជាបាយអោយវាចឹងទៅ ហើយគេបានអោយឈ្មោះថា អោយបាយ។ហើយក៏យើងបានយកមករវៃ។

ក៖ ចាសនិយាយទៅគឺយើងបានយកទឹកនឹងយកទៅដាក់ជាមួយនឹងទឹកនឹងមែនដែលរឺទេលោកយាយ?

ខ៖ ចាសៗ។

ក៖ ចាសនិយាយទៅគឺជាទឹកអង្ករនឹងមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពេលល្ងវនឹងគឺមិនដូចជានៅក្នុងជំនាន់ពីដើមនោះទេ។ ហើយសំរាប់ដើមធំធេតនឹងគឺគេបានយកមកដាក់ជារវៃ។ ហើយសំរាប់មួយនឹងគឺនៅខាងភ្នំឆត្រ័។ ហើយប្រសិនជាបណ្តាយនឹងគឺប្រហែលជា ៥០គីឡូ។នៅខាងភ្នំឆត្រ័នឹង។

ក៖ ចាសហើយចឹងសំរាប់មួយនឹងថាតើគេបានយកមកធ្វើអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ដើមត្រកួននឹងគឺគេបានយកមក ហើយនឹងបេះមកនឹងគឺយកមកកៀបដើម្បីនឹងធ្វើដេកចានប្រអប់របស់គេ។ ហើយសំរាប់មួយនឹងគឺគេបានហៅថា ចានស្មោរ។

ក៖ ចាសនិយាយទៅនេះហើយគឺជាលើកទីមួយហើយដែលខ្ញុំបានលឺថា ដើមសាប៊ូនឹងគឺគេយកមកធ្វើជាចានស្មោរបាន ហើយនឹងស្លឹកកាធំធេត នឹងគឺគេបានយកមកធ្វើជាចានស្មោរបានមែនដែលរឺទេលោកយាយ?

ខ៖ ចាសបានៗ។

ក៖ ចាសហើយចឹងសំរាប់មួយនឹងថាតើគេបានយកមកធ្វើនឹងនៅប្រទេសខ្មែររបស់យើងរឺក៏យ៉ាងមិចដែលទៅលោកយាយ?

ខ៖ ចាសនិយយាទៅសំរាប់មួយនឹងគឺនៅប្រទេសថៃចឹងហា សដចាស ពីព្រោះអីនឹងគឺភ្នំឆត្រ័ នៃប្រទេស ថៃរបស់យើង។ ហើយនៅពេលដែលយើងបានចប់សង្គ្រាមត្លែមនឹងនៅក្នុងឆ្នាំ ១៩៧៩ ហើយនឹងថ្ងៃទី ៧មករា នៅពេលលដែលបានចប់នឹងគឺឆ្នាំ ១៩៨០ នឹងគឺខ្ញុំបានទៅជុំរុំរបស់គេចឹង។

ក៖ ចាសហើយចឹងបានន័យថាសំរាប់លោកយាយបានទៅប្រទេសនឹងតែម្នាក់ឯងរឺក៏យ៉ាងមិចដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺយើងបានទៅគ្នានឹងគឺច្រើនដែល។

ក៖ ចាសហើយចឹងនៅពេលដែលលោកយាយបានទៅនឹងថាតើលោកយាយទៅដើម្បីអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅនៅពេលដែលយើងនឹងបានទៅនឹងគឺគេបានបើករបបរបស់យើងអោយយើង។ ហើយមានដូចជាអង្ករអោយយើងចឹងទៅ។ ហើយនៅពេលដែលយើងបានទៅបានហើយចឹងក៏យើងបានដឹកយកមកវិញចឹងទៅ។ ហើយនៅពេលដែលយើងបានទៅជុំរុំនឹងគឺយើងមានភាពរហាមខ្លាំងណាស់ ពីព្រោះអីនឹងនៅពេលដែលនៅក្នុងជំនាន់នឹងគឺមានមនុស្សនឹងគឺបានស្លាប់អស់ច្រើនខ្លាំងណាស់។

ក៖ ចាសហើយចឹងនៅពេលលោកយាយបានទៅជុំរុំនឹងថាតើលោកយាយបានអ្វីសំរាប់ធ្វើដំណើរដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅនៅពេលដែលយើងបានទៅគឺយើងបានជិះកង់។ ហើយនៅពេលដែលគេបានរំដោះបាន។ ហើយនៅពេលដែលយើងទៅនឹងគឺគេបានបើកអោយយើងនឹងនៅក្នុងម្នាក់នឹងអង្ករនឹងចំនួន១០គីឡូ។ ហើយគេបានបើកអោយយើងនឹងមានដូចជាទឹកត្រី ហើយនឹងអង្ករចឹងទៅ។ ហើយនៅពេលដែលយើងបានមកតាមផ្លូវនឹងគឺមានចោលនៅតាមផ្លូវដើម្បីផែតរបស់យើងដើម្បីចង់បានរបស់យើងទៀត។ ហើយនិយាយទៅសំរាប់នៅក្នុងជំនាន់នឹងគឺខ្លាំងណាស់ មានមនុស្សនឹងគឺស្លាប់អស់ច្រើនខ្លាំងណាស់។ ហើយនៅពេលដែលមកនឹងគឺមានមនុស្សនឹងគឺស្លាប់អស់ប្រហែលជារយនាក់នៅតាមផ្លូវដែលបានមក។

កៈ ចាសហើយចឹងចង់សួរលោកយាយបន្ថិចថានៅពេលដែលលោកយាយទៅចឹង ថាតើម្ដាយរបស់លោកយាយគាត់បានរស់នៅជាមួយនឹងនាក់ណាគេដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅនៅពេលដែលទៅនឹងគឺម្ដាយរបស់យើងនឹងគឺគាត់បានរស់នៅជាមួយនឹងក្មួយគេបានចិញ្ចឹមយើងរាល់ថ្ងៃនឹង។

កៈ ចាសហើយចឹងចង់សួរលោកយាយបន្ថិចថាសំរាប់នៅក្នុងជំនាន់នឹង ថាតើនៅពេលដែលគេបានជំលៀសលោកយាអោយទៅរស់នៅពីមួយកន្លែងទៅមួយកន្លែងនឹងថាតើគេបានអោយលោកយាយបានធ្វើការងារអ្វីខ្លះដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅគឺនៅក្នុងជំនាន់នឹងគឺយើងធ្វើការងារនឹងគឺឡើងយំតែម្ដង។ ពីព្រោះអីនឹងនៅពេលដែលគេបានអោយយើងនឹងធ្វើការងារនឹងគឺប្រហែលជា ៥កន្លះនឹងគឺបានអោយបានអោយយើងនឹងឡើងមកហូបបបរ។ ហើយនៅពេលដែលហើយចឹងទៅដល់ម៉ោង៦ ចឹងទៅគឺគេបានអោយយើងនឹងទៅដកកណ្ដាប់នឹងអោយបាន៥០កណ្ដាប់នៅក្នុងមួយម្នាក់។ ហើយនៅពេលដែលយើងនឹងបានដកហើយចឹងគឺគេបានអោយយើងនឹងទៅស្ទុងទៀតចឹង។ ហើយដកហើយចឹងគឺគេបានអោយយើងនឹងទៅចងកណ្ដាប់វិញទៀត។ ហើហាយប្រសិនជាយើងធ្វើមិនហើយអោយគេចឹង គឺថានៅក្នុងពេលមួយយប់ៗនឹងយើងមិនដែលបានដេកលក់បានស្រួលនោះទេ។

កៈ ចាសហើយចឹងសំរាប់ការហូបចុកនឹងគឺយ៉ាងមិចដែលទៅលោកយាយ ដូចជាគេបានអោយយើងនឹងហូបបាយដែលរឺទេលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់បាយវិញនឹងគឺមិនបានហូបនោះទេ គឺគេបានអោយយើងនឹងហូបតែបបរនោះទេ។ ហើយនៅពេលមុននឹងគឺគេបានអោយ១០កំប៉ុងនឹងគឺគេបានដាំអោយមួយខ្ទះ ។ ហើយមកដល់ឆ្នាំទី១ឆ្នាំទី២នៅក្នុងមួយខ្ទះនឹងគឺគេបានដាក់អោយយើងនឹងត្រឹមតែ៣កំប៉ុងនោះទេ។ ហើយសំរាប់បបរនឹងគឺមើលទៅគឺសុទ្ធតែទឹកនោះទេ។

កៈ ចាសហើយចឹងសំរាប់ការហូបចុកនឹងថាតើគេបានអោយហូបនឹងប៉ុន្មាននាក់ដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់មួយខ្ទះនឹងគឺគេបានអោយយើងនឹងហូបនឹងមានមនុស្សរាប់រាយនាក់។ ហើយគេបានចែកគ្នាទៀត។ សំរាប់មួយខ្ទះនឹងគឺគេបានដាក់អោយយើងនឹងត្រឹមតែ៣

កំប៉ុង ហើយគេបានចែកអោយយើងនឹងមានដូចជាអាក្រមែលបបររបស់គេនឹងគឺតិចតួចខ្លាំងណាស់ ហើយប្រសិនជាបានកាក់នឹងគឺបានកាក់បបរនឹងគឺបានត្រឹមតែ ២ស្លាបព្រានោះទេ។ ហើយប្រសិនជាក្មេងប្រហែលជាក្មួយឯងនឹងគឺគេមិនបានអោយយើងនឹងបានរស់នៅជុំម្ដាយហើយនឹងឪពុករបស់យើងនោះទេ។ ហើយនិយាយទៅគឺគេបានហៅយើងនឹងគឺជាកងសល័ត។ ហើយគេបានអោយយើងនឹងនៅមួយកន្លែងនោះទេ។ ហើយនិយាយទៅគឺយើងចេះតែទៅហើយ។

ក៖ ចាសហើយចឹងសំរាប់យើងនៅពេលដែលចល័តចឹងថាតើគេបានអោយយើងនឹងទៅកន្លែងណាខ្លះដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់រឿងនឹងគឺស្រាចតែគេបានប្រើយើង។ ហើយមិនដូចថាសព្វថ្ងៃនោះទេគឺនៅកន្លែងណាក៏បានតាមតែចិត្តរបស់យើង។ ហើយយើងចង់ធ្វើអ្វីក៏បានតាមចិត្តរបស់យើងបាននោះទេ។ហើយនៅក្នុងជំនាន់នឹងគឺយើងវេទនាខ្លាំងណាស់។

ក៖ ចាសហើយចឹងសំរាប់នៅក្នុងជំនាន់នឹងថាតើគេបានអោយឪពុកហើយនឹងម្ដាយរបស់លោកយាយ គាត់បានធ្វើការងារអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺពួកគាត់ធ្វើអ្វីមិនបាននោះទេ។ ណាមួយទៀតនឹងគឺពួកគាត់ពិការ។ ហើយដល់ពេលចឹងគឺគាត់ធ្វើអ្វីនឹងគឺមិនបាននោះទេ។ ហើយនៅពេលដែលហូបបាយនឹងគឺទាល់តែមានយើងដើម្បីបញ្ចុកគាត់កាន់ឈើគោងដែកចឹងទៅ។បានគាត់អាចហូបបាន។ ហើយសំរាប់យើងមានក្មួយអីនឹងគឺយើងអោយក្មួយរបស់យើងនឹងអោយទឹកអោយអីគាត់សំរាប់ហូបចឹងទៅ។ ហើយនិយាយទៅគឺចៅក្មួយនឹងគឺគេបានអោយវានឹងទៅរៀនទៀត។ដចាស ហើយនៅពេលដែលគេបានអោយវាទៅរៀនហើយចឹងគឺមិនមែនទៅរៀន ក ខ គ ឃ ង នោះទេគឺគេបានអោយវានឹងទៅរៀនទូអាចមន៍គោ។

ក៖ ចាសហើយនិយយាទៅខ្ញុំស្មានតែនៅក្នុងជំនាន់នឹងគឺគេបានអោយយើងនឹងទៅរៀនធម្មតាតែតាមពិតនឹងគឺគេបានអោយយើងនឹងទៅរៀនទូអាចម៍នោះទេមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅគឺគេបានអោយយើងនឹងទូអាចម៍គោនោះទេ។ ហើយនិយាយទៅនៅពេលដែលទូរនឹងគឺគេបានដាក់ចានធំអោយយើងទូរ។ ហើយនិយយាទៅគឺគេបានដាក់បាច់ធ្វើជីដើម្បីដាក់ស្រែចំការរបស់គេ។

កៈ ចាសហើយចឹងសំរាប់ក្មួយរបស់លោកយាយ ថាតើនៅក្នុងជំនាន់ប៉ុលពតនឹងថាតើគាត់មានអាយុប្រហែលជាប៉ុន្មានឆ្នាំដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងគឺគាត់មានអាយុនឹង ៩ឆ្នាំហើយ។ ហើយនិយយាទៅគឺគេបានអោយរៀនទូរអាចន៍គោ។ ហើយនៅពេលដែលវាបានមកវិញនឹងគឺដៃរបស់វានឹងបានប្រលាក់នឹងគឺគេបានអោយទៅលាងទឹកច្រើន ហើយនៅពេលដែលវាខ្លាចចឹងគេយករបស់វាដូចជាឈើអីចឹង។

កៈ ចាសហើយចឹងបានថាក្មេងៗនៅក្នុងជំនាន់មុននឹងគឺពួកគាត់ឆ្លាត ខ្លាំងណាស់ហើយប្រសិនជាយើងមិនបានដឹងហើយយើងបានចុះទៅជួយពួកគាត់ចឹងទៅក៏ពិបាកដែលមែនដែលរឺទេលោកយាយ?

ខៈ ចាសៗ។

កៈ ចាសហើយចឹងសំរាប់នៅពេលដែលគាត់បានចុះទឹកនឹងថាតើវាជាស្រះរឺក៏យ៉ាងមិចដែលទៅលោកយាយ?

ខៈ ចាសនិយាយទៅសំរាប់មួយនឹងគឺជាព្រែកនោះទេ។ ហើយនៅពេលដែលក្មួយឯងបានជិះតាមនឹងចឹងទៅបានដល់ត្រឹមនឹងចឹងទៅគឺដល់រោងតាគុយ ហើយនឹងបានមកដល់រោងបបររបស់គេចឹងទៅ។ ហើយសំរាប់នៅខាងនោះគឺគេបានហៅថាសង្កាត់ក្តល់ ហើយនៅក្នុងសង្កាត់ក្តល់នឹងគឺមាន៧ភូមិទៀត។

កៈ ចាសហើយនិយាយទៅសំរាប់លោកយាយបានដឹងទាំងអស់ ហើយក៏បានដឹងច្បាស់ទៀតមែនដែលរឺទេលោកយាយ?

ខៈ ចាសនិយយាទៅសំរាប់ភូមិនឹងគឺមានទាំងអស់ ៧ ភូមិ ក៏ប៉ុនតែអ្វីធំជាងគេនឹងគឺ ភូមិក្តល់សង្កាត់ដូនទាវ ហើយសំរាប់នៅខាងនោះគឺគេបានហៅភូមិតាក្តល់ ហើយសំរាប់នៅភូមិម្ខាងទៀតនឹងគឺគេបានហៅថា ភូមិតាក្តួច ហើយសំរាប់មួយខាងទៀតនឹងនៅខាងជើងនឹងគឺគេបានហៅភូមិ អូតានួច ហើយប្រសិនជានៅខាងស្តាំផុតពីភូមិនេះនឹងគឺគេបានហៅថា ភូមិចុងព្រែកហើយប្រសិនជាទៅខាងមុខទៀតនឹងគឺទៅខាងកើតនឹងគឺយើងទៅតាមមាត់ស្ទឹង។ គឺគេបានហៅថាភូមិតា លួត ហើយមួយកំណាត់ភូមិដូនទាវ នឹងគឺគេបានហៅថា ភូមិថ្កូវ ។

ក៖ ចាសនិយាយទៅសំរាប់ពីមុននឹងគឺខ្ញុំបានធ្លាប់លឺថា មានភូមិកន្ទួកដែល។ ហើយសំរាប់ពេលនេះនៅកន្លែងនេះយើងមានភូមិនឹងដែលមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ភូមិកន្ទួកនឹងប្រសិនជានៅខាង ភ្នំពេញនឹងក៏មានភូមិកន្ទួចដែល។

ក៖ ចាសនិយាយទៅសំរាប់ពេលដំបូងនឹងគឺខ្ញុំស្មានតែនៅខាង បាត់ដំបងរបស់យើងនឹងក៏មានភូមិកន្ទួចដែល។លោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់នៅខាងបាត់ដំបងរបស់យើងនឹងក៏មានភូមិកន្ទួចដែល។

ក៖ ចាសហើយចឹងសំរាប់លោកយាយ ថាតើហេតុអ្វីបានជាលោកយាយបានស្គាល់ភូមិកន្ទួចរបស់យើងដែលទៅលោកយាយ?

ខ៖ ចាសនិយយាទៅសំរាប់នៅក្នុងជំនាន់នឹងគឺយើងបានទៅដុតនុំពុម្ព ខ្មែររបស់យើង។ ហើយសំរាប់មួយគឺយើងបានលក់នឹងចំនួន ៥កាក់។ ហើយសំរាប់២ពុម្ពនឹងគឺ១រៀល។ ហើយដល់ពេលចឹងក៏ខ្ញុំបានទៅលក់នឹងនៅទីកន្លែងនឹងតែម្តង។

ក៖ ចាសហើយនិយាយទៅសំរាប់រឿងនៅខាងកំពង់កន្ទួតនឹងគឺម្តាយហើយនឹងជីដូនជីតារបស់លោកយាយគឺគាត់ជានាក់ស្រុកមួយនឹងមែនដែលរឺទេលោកយាយ?

ខ៖ ចាស១ ហើយនិយយាទៅសំរាប់រឿងមួយនឹងគឺយើងចេះតែទៅរកចឹងទៅ។ ហើយនៅពេលដែលយើងនឹងបានទៅរកកន្លែងណាដែលស្រលះ ហើយនឹងមានកន្លែងធំចឹងទៅគឺយើងចេះតែទៅរស់នៅទីកន្លែងនឹងចឹងទៅ។ ហើយសំរាប់យើងនៅប្អូនពៅបង្អស់នឹងគឺគាត់ជានៅបំរើចឹងទៅ។ ហើយនិយាយទៅគឺយើងចេះទៅរកស៊ីចឹងទៅ។ ហើយើសំរាប់យើងនឹងគឺយើងបានដើររកនឹងតាំងពីយើងបានដឹងក្តីរហូតដល់មានអាយុ ៨៣ ឆ្នាំហើយមកដល់នឹង។

ក៖ ចាសនិយាយទៅសំរាប់មើលទៅកាន់លោកយាយគឺនៅរឹងមាំខ្លាំងណាស់ លោកយាយ?

ខ៖ ចាសនិយយាទៅមើលមកខ្ញុំនឹងគឺរឹងមាំតែនៅខាងក្រៅនោះទេ។ ហើយសំរាប់នៅក្នុងកាយរបស់ខ្ញុំនឹងគឺអន់ហើយ។ ហើយប្រសិនជាលោកធាតុទាំងឡាយនឹងគឺយើងមើលទៅមិនទៀងទាត់នោះទេ។ ហើយនិយាយទៅនៅពេលដែលមើលទៅគឺមើលរាងអូសនឹងគឺមើលមានប្រយោជន៍អ្វីនោះទេ។គឺយើងរកមិនឃើញតែម្តង។ ហើយនិយាយទៅគឺមានតែព្រះពុទ្ធព្រះធម៌ហើយនឹងព្រះសង្ឃនោះទេដែលជាទីនឹករលឹក។ ហើយបាននិយាយថាបានដាក់នាមអោយ

យើងថា យើងនឹងគឺបានអង្គុយស្ងាត់តែម្នាក់ឯងចឹងទៅ ហើយក៏គេបានឃើញយើងក៏បានទិញវិទ្យុមួយដើម្បីទុក្ខអោយយើងនឹងបានស្តាប់។ ហើយនៅពេលដែលអស់ថ្មចឹងទៅក៏យើងនឹងលេងបានស្តាប់ទៀតចឹងទៅ។ ហើយនៅពេលគេបានឃើញយើងមិនបានស្តាប់ចឹងក៏គេបានសួរយើងថា ហេតុអ្វីបានជាលោកយាយមិនស្តាប់វិទ្យុចឹងទៅ ហើយយើងក៏បានប្រាប់គេវិញថាវិទ្យុរបស់យើងនឹងគឺវាបានអស់ថ្មហើយ។ ហើយដល់ពេលចឹងបានយើងនឹងបានទិញថ្មរបស់គេទៀតចឹងបានយកមកដាក់ដើម្បីបានស្តាប់ទៀតចឹងទៅ។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថា នៅពេលដែលគេបានជំលៀសទៅដល់ទន្លេរបឹងខ្វឹងនឹងថាតើគេបានអោយធ្វើការងារអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយយាទៅសំរាប់ការងារនឹងគឺមិនចង់និយាយនោះទេ។ ហើយនៅពេលដែលគេបានអោយយើងនឹងទៅខ្វឹងនឹងគឺគេបានអោយយើងនឹងកាប់ដី ហើយនឹងជីករណ្តៅទៀតហើយនឹងកាប់ឪឡឹកទៀតនឹងដាំត្រសក់អោយគេទៀត។

ក៖ ចាសហើយចឹងសំរាប់គេបានអោយលោកយាយបានធ្វើការងារនឹងគឺច្រើនខ្លាំងណាស់ហើយសំរាបការហូបចុកនឹងថាតើគេបានអោយលោកយាយបានហូបអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺគេបានអោយយើយងនឹងហូបតែបបរនោះទេ។ តែសំរាប់នៅទីកន្លែងនឹងគឺគេបានអោយយើងនឹងហូបពោតដែល។ ហើយនៅពេលដែលយើងបានពោតយកមកហើយចឹងគឺយើងបានយកមកដាក់ជាមួយនឹងបបរចឹងទៅក៏មើលបបររបស់យើងនឹងគឺវារាងគោកបន្តិច។

ក៖ ចាសនិយាយទៅគឺគេបានអោយយើងនឹងហូបពោតដែលជាមួយនឹងបបរដែលមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពោតនឹងគឺគេបានយកមកបុកដូចជាអង្ករ។ ហើយនៅពេលដែលគេបានយកមកពោតមកហើយបុកជាមួយនឹងអង្ករតែម្តង។

ក៖ ចាសហើយចឹងសំរាប់ពេលនឹងថាតើលោកយាយបានទៅនឹង លោកយាយទៅតែម្នាក់ឯងសុទ្ធតែម្តងមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅគឺនៅពេលដែលយើងទៅនឹងគឺយើងបានទៅមួយគ្រួសាររបស់យើងតែម្តង។ ហើយសំរាប់នាក់នៅស្រុកនឹងក៏គេបានទៅដែល។ ហើយនៅពេលដែលទៅនឹងគឺគេបានទៅជាង ១០០នាក់។

ក៖ ចាសហើយចឹងនៅពេលដែលយើងទៅជាង១០០នាក់នឹង ថាតើពេលទៅនឹងគឺគេបានអោយយើងនឹងជិះអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅគឺយើងដើរតែម្តង។

ក៖ ចាសនិយាយទៅសំរាប់ពីនេះនឹងគឺឆ្ងាយខ្លាំងណាស់ ពីព្រោះអីនឹងគឺខ្ញុំបានស្គាល់ដែល។ ពីកន្លែងនឹងគឺវាឆ្ងាយគួរសមដែល។លោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺយើងបានដើរ ហើយនិយាយទៅនៅពេលដែលយើងនឹងដើរពីខាងខេត្តបាត់ដំបងនឹងគឺដើររហូតពីភ្នំក្រពើ។ ហើយនៅពេលដែលយើងដើរពីភ្នំក្រពើហើយនឹងទៅដល់ស្ទឹង។ហើយនឹងដើរដល់ភ្នំអំពើនឹងបានគេបានអោយយើងនឹងឈប់សំរាក់ម្តង។

ក៖ ចាសហើយចឹងនៅពេលដែលយើងដើរនឹងថាតើយើងបានដើរប៉ុន្មានថ្ងៃបានយើងបានឈប់សំរាក់ម្តងដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅនិយាយទៅគឺយើងបានដើរតាំងពីម៉ោង២ នឹងគឺយើងបានដើរកាត់នឹងផ្លូវប្រដាក់នឹង ហើយនៅពេលដែលម៉ោង៥អីនឹងបានយើងនឹងបានទៅដល់។ ហើយបានដល់បឹងខ្ទឹង។ ហើយសំរាប់យើងនឹងមានភាពតស៊ូខ្លាំងណាស់ ពីព្រោះអីនឹងគឺយើងបានដើរនឹងគឺតាំងពីយើងនឹងកំព្រាតាំងពីអាយុ៧ឆ្នាំនឹងក៏យើងបានដើររហូត។

ក៖ ចាសហើយចឹងចង់សួរលោកយាយបន្តិចថាសំរាប់លោកយាយនៅពេលដែលលោកយាយបានទៅដល់នឹងថាតើមួយនឹងគឺជាលើកចុងក្រោយរឺក៏យ៉ាងមិចដែលទៅលោកយាយ?

ខ៖ចាសនិយាយទៅគឺអត់នោះទេ។ ហើយនិយយាទៅមួយនឹងគឺជាឆ្នាំ ទី២ហើយ។

ក៖ ចាសហើយចឹងសំរាប់មួយនឹងគេបានហៅកន្លែងនឹងជាអ្វីដែលទៅលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់មួយនឹងគឺគេបានហៅថាកន្លែងជាព្រៃដាច់។ ហើយសំរាប់មួយនឹងគឺគេបានហៅទំនាប់ចឹងហាសាចស ហើយនិយាយទៅសំរាប់កន្លែងនឹងគឺនៅឆ្ងាយខ្លាំងណាស់។

ក៖ ចាសហើយចឹងសំរាប់មួយនឹងគឺនៅទីកន្លែងណាដែលទៅលោកយាយ គឺខ្ញុំមិនដែលបានស្គាល់នោះទេលោកយាយ ហើយសំរាប់មួយនឹងនៅក្នុងខេត្តបាត់ដំបងរបស់យើងដែលមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់មួយនឹងនៅក្នុងខេត្តបាត់ដំបងរបស់យើងដែល។ ហើយនិយាយទៅឆ្ងាយដែល។ ហើយសំរាប់កន្លែងនឹងគឺគេបានហៅថាស្ទឹងព្រះ។សំរាប់នៅទីកន្លែងនឹង។ ហើយសំរាប់វែនតាមួយនេះនឹងគឺយើងមិនមានប្រាក់ដើម្បីនឹងបានទិញខ្លួនយើងនោះទេ។ គឺមានគ្រូម្នាក់ដែលគាត់មានឈ្មោះថា វិបុល ហើយគាត់បានធ្វើប្រូវិសើ ហើយនឹងបានមកបង្រៀនយើងកាល់ពីនៅក្នុងជំនាន់សង្គម។នៅភូមិក្តល់របស់យើង។ ហើយសំរាប់ខ្ញុំនឹងគឺជានាក់ដែលលក់នុំនឹងគឺខ្ញុំបានស្គាល់។ ហើយនៅពេលដែលដល់ជំនាន់ប៉ុលពតមកដល់នឹងគឺគេបានអោយគាត់នឹងទៅដាំបបរនឹងនៅខាង ត្រាច។ ហើយសំរាប់នៅទីកន្លែងនឹងគឺគេបាននិយាយថាគាត់ម្នាក់នឹងគឺពីមុននឹងធ្វើការងារធំខ្លាំងណាស់ នៅពេលដែលគេបានហៅយើងទាំងអស់គ្នានឹងទៅប្រជុំនឹងគឺគាត់បានធ្វើជាមិនដឹងចឹងហាសាចស ហើយសំរាប់ខ្ញុំក៏បានប្រាប់គេថា សំរាប់គាត់នឹងគឺមិនបានធ្វើអ្វីនោះទេ គឺគាត់ពីមុននឹងគឺគាត់ជារកស៊ីរត់រម៉ត់តែប៉ុននឹង។ ហើយដល់ពេលចឹងក៏គេបានសួរមកកាន់ខ្ញុំវិញថា ហេតុអ្វីបានដឹងរឿងរបស់គាត់ចឹង ហើយខ្ញុំក៏បានប្រាប់ទៅកាន់គាត់វិញថា ពីព្រោះអីនឹងគឺគាត់បានរស់នៅខាងខ្ញុំ។ហើយដល់ពេលចឹងគឺខ្ញុំបានដឹងថាគាត់នឹងគឺជានាក់ដែលរត់រម៉ត់តែម្តង។ ហើយណាមួយទៀតនឹងនៅពេលដែលខ្ញុំបានលក់នុំនឹងគឺខ្ញុំតែងតែហៅគាត់ដើម្បីអោយជួយខ្ញុំហើយនឹងដឹកខ្ញុំអោយទៅលក់នុំនៅផ្សារ។ ហើយនៅពេលដែលយើងបានចប់មកនឹងគឺរហូតមកដល់សព្វថ្ងៃនឹងគឺគាត់នៅខាងផ្សារលើ ហើយសំរាប់គាត់បានអត្រែក ហើយ។ ហើយដល់ពេលចឹងគឺយើងបានជួយគាត់ក៏គាត់អរគុណយើងដែល។ ហើយមានម្នាក់ទៀតនឹងក៏គាត់ជាគ្រូដែលហើយសំរាប់ពួកគាត់ប្រសិនជាបានដឹងនឹងថាពួកគាត់ជាគ្រូបង្រៀននឹងគឺដឹងតែស្លាប់ហើយ ហើយនៅពេលដែលយើងបានជួយគាត់ចឹងក៏គាត់បានអោយយើងជាកាដូវែនតាអោយមកយើង។ ហើយនៅពេលយើងនឹងបានសួរគាត់ថាលោកគ្រូវែនតានឹងអស់ប៉ុន្មាន ហើយគាត់បាននិយាយថាកុំអោយនាក់ដែលនៅខាងក្រោយនឹងបាននិយាយ។ ហើយដល់ពេលចឹងគឺប្រហែលជា១៥រៀល។ ហើយនៅពេលដែលខ្ញុំបានក្រវៀសភ្នែករបស់ខ្ញុំនឹងគឺវាតែងតែហូរទឹកភ្នែកចេញមក។ ហើយនៅពេល

ដែលក្រវៀសនឹងគឺយើងក្រវៀសមិនអស់នោះទេ។ ពីព្រោះអីនឹងគឺយើងជាជនក្រីក្រ។ ហើយសំរាប់គេបានមកដឹកយើងនឹងពីកន្លែងនេះនឹងរហូតដល់ពេទ្យ។ហើយគេបានកាត់អោយយើង។ ហើយនៅពេលដែលមកនឹងគឺវះអោយយើង។

ក៖ ចាសហើយចឹងសំរាប់ភ្នែករបស់វាគឺត្រូវបានមើលឃើញនោះទេនៅពេលដែលវះនឹងមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅនៅពេលដែលមិនទាន់មិនបានវះកាត់នឹងគឺថាភ្នែករបស់យើងនឹងគឺមើលទៅមិនទាន់ឃើញនោះទេ។ដូចជាមានអ្វីមកបាំងភ្នែករបស់យើង។ ហើយនៅពេលដែលយើងបានវះហើយចឹងទៅក៏បានសាសន៍ចឹងទៅ ហើយក៏លោកគ្រូបានទិញវ៉ែនតាមួយនឹងអោយយើងបានពាក់ចឹងទៅ។ ហើយសំរាប់យើងនឹងបានពាក់វ៉ែនតានឹងគឺអស់រយះពេល ១០ឆ្នាំមកហើយ។

ក៖ ចាសហើយចឹងសំរាប់ភ្នែករបស់លោកយាយ ថាតើមូលហេតុអ្វីដែលទៅលោកយាយបានជាចេះតែហូរចឹងទៅលោកយាយ?

ខ៖ ចាសនិយាយទៅគឺយើងចេះតែហៀលទឹកភ្នែក នៅពេលដែលមានខ្យលមកប៉ះភ្នែករបស់យើង។

ក៖ ចាសនិយាយទៅសំរាប់ពេទ្យនឹងគឺគាត់មិនបាននិយាយអ្វីអោយយើងនឹងនោះទេមែនដែលរឺទេលោកយាយ?

ខ៖ ចាសនិយាទៅសំរាប់ពេទ្យនឹងគឺគេបាននិយាយថាអោយយើងនឹងបានដាក់ថ្នាំភ្នែក។ សចាស ហើយនៅពេលដែលដាក់នឹងគឺយើងបានអោយគេដាក់ថ្នាំនឹងគឺអោយអាដែលមានតម្លៃថោកជាងគេប្រហែលជា ១០០០ ។ ហើយសំរាប់យើង២ទៅ៣ថ្ងៃនឹងគឺយើងបានដាក់ម្តង។ ពីព្រោះអីនឹងគឺយើងក្រមិនមាននោះទេ តែយើងមានភាពតស៊ូ។ ហើយនៅពេលដែលដល់ថ្ងៃណាយមរាជនឹងគឺគេបានអោយយើងនឹងទៅនឹងគឺយើងទៅតាមគេចុះចឹងទៅ។ ពីព្រោះអីនឹងគឺយើងមិនស្តាយនោះទេ។ ហើយសំរាប់ខ្ញុំមានតែព្រះពុទ្ធព្រះធម៌ ព្រះសង្ឃដែលខ្ញុំតែងតែនឹករលឹករហូតមក។ ហើយនិយាយទៅគឺគ្មានអ្វីដែលខ្ញុំអាចនឹងពឹងបាននោះទេ។ ពីព្រោះអីនឹងនៅពេលដែលខ្ញុំបានមកនឹងគឺមានតែបាតដៃនឹងទទេ ហើយនៅពេលដែលទៅវិញនឹងក៏មានតែបាតដៃទទេដែល។ ហើយយើងក៏មិនមានទ្រព្យសម្បត្តិយកទៅវិញដែល។ ហើយមិនថានាក់មានប៉ុនណា ហើយនឹងក្រប៉ុនណានោះទេ។ ហើយគេមានក៏ដោយក៏នៅពេលដែលគេ

បានទៅវិញនឹងគឺមានតែបាតដៃទទេដែល។ ហើយដូចថាសំរាប់សព្វថ្ងៃនឹងដែលបងប្អូនរបស់គេ ហើយនឹងញ្ញាតិរបស់គេនឹងគឺគេបានអោយមកយើងនឹងបន្តិចបន្តួចនឹងបានហូបព្រឹកចឹងទៅ។ ពីព្រោះអីនឹងគឺយើងមិនបានដាំបានពេលព្រឹកនោះទេ។ ពីព្រោះអីនឹងសំរាប់កូនហើយនឹងក្មួយរបស់យើងដែលគាត់បានចិញ្ចឹមយើងនឹងគឺគាត់មិនបានអោយយើងនឹងធ្វើនោះទេ ពីព្រោះអីនឹងខ្លាចថាយើងនឹងរលាស់ដៃអីចឹងទៅ ហើយនឹងមានបញ្ហា។ហើយនៅពេលដែលលោកគាត់បាននិមន្តមកចឹងទៅគឺខ្ញុំបានធ្វើបុណ្យដាក់ ១០០០៛ ចឹងទៅ។ ហើយនិយាយទៅគឺយើងបានញ្ញាតិនោះទេដែលគាត់បានអោយយើង។ ហើយសំរាប់ថ្ងៃខ្លះនឹងគឺគាត់មានចិត្តច្រើននឹងគឺគេបានអោយយើងនឹងចំនួន ៥០០០៛ចឹងទៅ។ ហើយសំរាប់ថ្ងៃខ្លះនឹងគេបានអោយយើងនឹងម្នាក់ ២០០០៛ ទៅ ៥០០០៛ ចឹងទៅគឺយើងបានរហូដល់ ១០០០០៛ ទៅ ២០០០០៛ចឹងទៅគឺយើងយកមកដើម្បីនឹងសន្សំទុកចឹងទៅ។ ហើយនៅពេលដែលដល់ថ្ងៃសល៍ចឹងទៅគឺយើងបានដាក់បុណ្យដើម្បីបានទៅវត្ត។ ហើយសំរាប់រាល់ថ្ងៃនឹងគឺយើងបានរស់នៅដោយសារតែញ្ញាតិរបស់យើងនោះទេ។ ហើហាយប្រសិនជានាក់ស្រួលៗអីនឹងនៅពេលដែលខ្ញុំបានរស់នៅក្រឡាសធំគឺយើងចេះតែទៅហើយ។ដើម្បីបានបុណ្យ។ ហើយសំរាប់ដូចជាក្មួយឯងស្រុកកំណើតនឹងនៅទីកន្លែងណាដែល ។

ក៖ ចាសនិយាយទៅសំរាប់ស្រុកកំណើតរបស់ខ្ញុំនៅខាងបាត់ដំបងដែល។លោកយាយ?

ខ៖ ចាសហើយចឹងសំរាប់នៅខាងបាត់ដំបងរបស់យើងនឹងនៅសង្កាត់អ្វីដែលទៅ។

ក៖ ចាសសំរាប់ខ្ញុំរស់នៅខាងសង្កាត់ផ្លាស្លា លោកយាយ។

ខ៖ ចាសហើយចឹងសំរាប់ក្មួយឯងមានបានស្គាល់ លោកយាយ សឿន ហើយនឹងលោកយាយលក្ខណ ដែលរឺទេ?

ក៖ ចាសនិយាយទៅគឺខ្ញុំមិនបានស្គាល់ពួកគាត់នោះទេលោកយាយ។

ខ៖ ចាសហើយចឹងក្មួយឯងមានបានស្គាល់ លោកតា សំសាន្ត ដែលរឺទេ?

ក៖ ចាសនិយយាទៅសំរាប់ខ្ញុំបានរស់នៅខាងផ្កាស្លា នៅខាងបឹងឈូក នោះទេលោកយាយ។

ខ៖ ចាសនិយាយទៅសំរាប់បឹងឈូកនឹងនៅខាងជើង ហើយសំរាប់វត្ត សំសាន្ត នៅខាងត្បូង ។ ហើយបន្ទាប់ពីផ្សារបឹងឈូកនឹងមកដល់វត្តដំណាក់ ល្ងង ហើយបន្ទាប់ពីវត្តដំណាក់ល្ងង នឹងមកហើយចឹងគឺវត្តសំសាន្ត ។ ហើយនិយយាទៅគឺយើងទៅផ្លូវផ្សេងវិញ។ ហើយនិយាយទៅគឺ

ថាបន្ទាប់ពីវត្តសំសាន្ត ហើយចឹងបានមកដល់វត្តដំរីស ហើយបានមកដល់វត្តកំផែន ហើយសំរាប់វត្តសំសាន្ត នឹងគឺវានៅទទឹមគ្នា។ ហើយនិយាយទៅនាងនៅទីកន្លែងនឹងសោះហេតុអ្វីបានជាមិនស្គាល់។

ក៖ ចាសនិយាយទៅនិយាយទៅដោយសារតែខ្ញុំមិនដែលបានទៅវត្តច្រើន។លោកយាយ?

ខ៖ ចាសនិយាយទៅគឺថានៅពេលដែលទៅវត្តមានបានស្គាល់ភូមិស្រាស្រ្តច្បាស់ដែលរឺទេ?

ក៖ ចាសនិយាយទៅសំរាប់ពេលខ្លះនឹងនៅពេលដែលគេបានសួរខ្ញុំមកនឹងគឺខ្ញុំមានអារម្មណ៏ថា ផាំម្តងដែល។ពីព្រោះអីនឹងគឺខ្ញុំមិនដែលទៅវត្ត។ហើយណាមួយទៀតនឹងគឺខ្ញុំនិយាយតាមត្រង់ ហើយនៅពេលដែលខ្ញុំបានជិះទៅធ្វើការក៏ខ្ញុំមិនសូវជាស្គាល់ដែល។ ហើយសំរាប់មួយនេះគឺខ្ញុំចេះតែជិះតែមើលចឹងទៅក៏សួរគេចឹងទៅលោកយាយ?

ខ៖ចាសនិយាយទៅនៅពេលដែលយើងជិះទៅដល់ក្រោយនេះនឹងគឺគេបានហៅថា វត្តក្តុល់ហើយ។ហើយទៅបន្តិចទៀតនឹងគឺគេបានហៅវត្តតាកុយ ហើយយើងជិះទៅមុខបន្តិចទៀតចឹងទៅយើងជិះទៅត្បូងនឹងគឺយើងបានទៅដល់ផ្សារនៅខាងបាត់ដំបងហើយ។ ហើយប្រសិនជាយើងបានមកខាងនេះយើងដល់វត្ត។

ក៖ ចាសហើយចឹងសំរាប់លោកយាយមានអ្វីចង់បន្ថែមទៀតដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ខ្ញុំគ្មានអ្វីទៀតនោះទេ។

ក៖ ចាសនិយយាទៅសំរាប់លោកយាយមានអ្វីចង់ផ្តាំទៅកាន់ក្មេងជំនាន់ក្រោយរបស់យើងទៀតដែលរឺទេលោកយាយ?

ខ៖ ចាសនិយាយទៅសំរាប់ក្មេងសព្វថ្ងៃនឹងគឺគេមិនបានជឿនោះទេ។ ហើយនិយាយទៅគឺគេមិនបានជឿខ្ញុំនោះទេ។

ក៖ ចាសហើយចឹងសំរាប់លោកយាយអាចផ្តល់ដំបូលមានអោយពួកគាត់នៅក្នុងសំលេងមួយនេះបាន។លោកយាយ?

ខ៖ ចាសនិយាយទៅគឺខ្ញុំមិនមាននោះទេ គឺខ្ញុំមានតែប៉ុននឹងឯង ពីព្រោះអីនឹងគឺយើងភ្លេចអស់ហើយ។នៅក្នុងជំនាន់ប៉ុលពតនឹងគឺខ្ញុំបានភ្លេចអស់ហើយចាស។

ក៖ ចាសហើយចឹងអរគុណច្រើនលោកយាយ ចឹងជំរាបលោកយាយចាស៕